# ឧបសម្ព័ន្ធទី ៥
## គោលការណ៍សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

## I- គោលបំណង

- ដើម្បីធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា (ច.ប.ក) និងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ។
- ដើម្បីលើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយ ។
- ដើម្បីអនុវត្តនូវមាត្រា ៧៤ មាត្រា ៧៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។
- ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន មានភាពអព្យាក្រឹត ក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កំណត់នូវគោលការណ៍មួយចំនួន សម្រាប់ប្រព័ន្ធផ្សព្វផ្សាយទាំងរដ្ឋ ទាំងឯកជន ដូចខាងក្រោម ។

## II-គោលការណ៍ទូទៅ

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងដែលអាចទទួលយកបាននូវលទ្ធផលនៃការបោះឆ្នោត អ្នកយកព័ត៌មានជាតិ ( រដ្ឋ និងឯកជន ) និងអន្តរជាតិ មានតួនាទីសំខាន់ក្នុងការប្រមូលព័ត៌មាន និងរាយការណ៍អំពីដំណើរការបោះឆ្នោតទូទាំងប្រទេស ។

ដើម្បីឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានលក្ខណៈប្រជាធិបតេយ្យ និងតម្លាភាព គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចេញគោលការណ៍សំរាប់គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងចូលរួមយកព័ត៌មាន ក្នុងដំណាក់កាលនីមួយៗនៃការបោះឆ្នោត ដូចខាងក្រោម ៖

១_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ មិនលំអៀង និងដោយមានការថ្លឹងថ្លែងអោយមានតុល្យភាព ។

២_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលផ្តល់ព័ត៌មានអំពីការបោះឆ្នោត ត្រូវតែផ្ទៀងផ្ទាត់អំពីប្រភពព័ត៌មានភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍ ។

៣_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែផ្តល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សម្រាប់អ្នកបោះឆ្នោត ។

៤_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវជៀសវាងការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា និងត្រូវថ្លឹងថ្លែងជាមុន មុននឹងធ្វើការផ្សព្វផ្សាយ ។

៥_ ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកគ្រប់គ្រងត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាព ចូលរួមធ្វើឱ្យការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ តាមរយៈការផ្តល់ព័ត៌មានអំពីការបោះឆ្នោត និងចាត់ទុកព័ត៌មានអំពីការបោះឆ្នោតជាព័ត៌មានអាទិភាព ។

៦_ អ្នកសារព័ត៌មានមិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួន ដោយសារតែអំណោយផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ ។

៧_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវមានភារកិច្ច និងការទទួលខុសត្រូវ ក្នុងការស៊ើបអង្កេត និងរាយការណ៍នូវបញ្ហាដែលទាក់ទងដល់ការបោះឆ្នោតឱ្យបានត្រឹមត្រូវ ដើម្បីរក្សាស្ថេរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ។

៨_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវស្វែងរក និងត្រូវផ្សព្វផ្សាយព័ត៌មាន អំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត ។

៩_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប នៅក្នុងដំណើរការបោះឆ្នោត ។

១០_ គ.ជ.ប លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងលក្ខណៈជាដៃគូ ជាមួយ គ.ជ.ប និងសង្គមស៊ីវិល ដើម្បីធ្វើការផ្តល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត ។

១១_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវតែជៀសវាងការផ្តល់ព័ត៌មាន ដែលពាក់ព័ន្ធនឹងការរើសអើងដល់ស្ត្រីភេទ និងជនពិការ ។

១២_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មាន អំពីសារៈសំខាន់ នៃការចូលរួមរបស់ស្ត្រី និងជនពិការក្នុងជីវភាពសង្គម និងនយោបាយដើម្បីបង្កើនការយល់ដឹងជាសាធារណៈ ។

១៣_ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជន ត្រូវតែធ្វើការបែងចែកឱ្យបានច្បាស់ ក្នុងការផ្សព្វផ្សាយព័ត៌មាន អំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោតដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ ។

១៤_ អ្នកយកព័ត៌មាន អ្នករាយការណ៍ និងអ្នកធ្វើអត្ថាធិប្បាយ ត្រូវជៀសវាងសំដែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថតាមរយៈការលើកដាក់សំលេង ឬកិរិយាបថជាក់ស្តែងផ្សេងទៀត ។

១៥_ ការផ្សព្វផ្សាយដែលមានលក្ខណៈបរិហារកេរ្តិ៍គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយនោះ មានសិទ្ធិប្តឹងពីបទបរិហារកេរ្តិ៍ ឬការ

ប្រមាថមើលងាយ ឬ/និងសុំឱ្យអ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហារកេរ្តិ៍នោះ ធ្វើការកែតម្រូវ ឬបញ្ឈប់ការផ្សព្វផ្សាយនូវព័ត៌មានទាំងនោះ ។ ក្នុងករណីនេះ អ្នកផ្សព្វផ្សាយ ឬជនដែលបានបរិហារកេរ្តិ៍ ត្រូវធ្វើការឆ្លើយតបទៅនឹងគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយនោះ ឬក៏ធ្វើការកែតំរូវលើការផ្សព្វផ្សាយព័ត៌មានឱ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន ។ ការផ្សព្វផ្សាយព័ត៌មានឡើងវិញ អំពីខ្លឹមសារកែតំរូវ ត្រូវផ្សព្វផ្សាយក្នុងរយៈពេលប្រហែលគ្នានឹងរយៈពេលដែលបានផ្សព្វផ្សាយបរិហារកេរ្តិ៍ ។

១៦_ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ត្រូវបង្ហាញនូវកំរិតគុណភាពខ្ពស់ នៃវិជ្ជាជីវសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗ ឱ្យបានសមរម្យ ពិតប្រាកដ និងឥតលំអៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសម្រាប់គណបក្សនយោបាយ ដែលចូលរួមក្នុងការបោះឆ្នោតទាំងអស់ ។